CITY OF LONG BEACH **PRESS RELEASE**

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី 21 ខែឧសភា ឆ្នាំ 2021
ទំនាក់ទំនង ៖ មជ្ឈមណ្ឌលព័ត៌មានរួម នៃសាលាក្រុងឡុងប៊ិច, 562.570.NEWS, jic@longbeach.gov

សម្រាប់ការផ្សព្វផ្សាយភ្លាមៗ

# សាលាក្រុងឡុងប៊ិច ចាប់ដៃគូជាមួយ មណ្ឌលសិក្សាសាមគ្គី ឡុងប៊ិច ដើម្បីរៀបចំគ្លីនិកចាក់វ៉ាក់សាំង នៅក្នុងបរិវេណសាលា

ឡុងប៊ិច, CA - នាយកដ្ឋានសុខាភិបាល និងសេវាមនុស្ស នៃសាលាក្រុងឡុងប៊ិច បានចាប់ដៃគូជាមួយ មណ្ឌលសិក្សាសាមគ្គី ឡុងប៊ិច (LBUSD) ដើម្បីរៀបចំគ្លីនិកចាក់វ៉ាក់សាំង នៅតាមទីធ្លាសាលារៀន មួយចំនួន ជាផ្នែកនៃការប្តេជ្ញាចិត្ត ជាបន្តរបស់សាលាក្រុង ក្នុងការធានាឱ្យអ្នកគ្រប់គ្នាអាចចាក់វ៉ាក់សាំង COVID-19 បាន ។

ចៅហ្វាយក្រុង រ៉ូប៊ើត ហ្គាសៀ (Mayor Robert Garcia) បាននិយាយថា «យើងខ្ញុំមានមោទកភាព ក្នុងនាមជាដៃគូ របស់ LBUSD ដើម្បីរៀបចំគ្លីនិកចាក់វ៉ាក់សាំងទាំងនេះ នៅតាមទីតាំងសាលារៀន នៅមូលដ្ឋានរបស់យើង។» «យើងខ្ញុំនឹងបន្តរក្សាឱ្យមាន ភាពច្នៃប្រឌិត និងធ្វើការជាមួយ ដៃគូសហគមន៍របស់យើង ដើម្បីផ្តល់លទ្ធភាពទទួលបានវ៉ាក់សាំង កាន់តែច្រើនឡើង នៅទូទាំងទីក្រុងរបស់យើង ។»

គ្លីនិកចាក់វ៉ាក់សាំង តាមសាលារៀន នឹងដំណើរការ នៅក្នុងបរិវេណ LBUSD ដូចខាងក្រោមនេះ រហូតទាល់តែមានសេចក្តីជូនដំណឹង បន្ថែមទៀត ៖

- វិទ្យាល័យ ខាប្រិលឡូ (Cabrillo High School) នៅថ្ងៃសៅរ៍ ពី 10 ព្រឹក ដល់ម៉ោង 1 រសៀល
- បឋមសិក្សា ហ្គ្រាន (Grant Elementary) នៅថ្ងៃពុធ និងថ្ងៃសុក្រ ពីម៉ោង 10:30 ព្រឹក ដល់ម៉ោង 12:30 ថ្ងៃ
- អនុវិទ្យាល័យ វ៉ាស៊ីងតោន (Washington Middle School) ថ្ងៃអង្គារ និងថ្ងៃព្រហស្បតិ៍ ពីម៉ោង 2:30 រសៀលដល់ម៉ោង 4:30 ល្ងាច

ទីតាំងនីមួយៗ មានសមត្ថភាពទទួលចាក់វ៉ាក់សាំង ជូនអ្នកដើរចូលមកចាក់ បានប្រមាណ 100 នាក់ ក្នុងមួយម៉ោង ដោយផ្អែកលើវាំងសាំងមាននៅនឹងកន្លែង ហើយនឹងមានផ្តល់ជូន វ៉ាក់សាំង Pfizer និង Moderna ពីរដូស ព្រមទាំង Janssen/Johnson and Johnson មួយដូស ។ ក្នុងករណីដែលអ្នកមកណាត់ចាក់ ដោយការដើរចូលមក ត្រូវបានទទួលទាំងអស់ នៅថ្ងៃណាមួយ, នោះគេនឹងទទួលបានព័ត៌មាន អំពីជម្រើសទីតាំងចាក់វ៉ាក់សាំង ចល័ត ឬ កំណត់ពេលឱ្យមកចាក់ នាពេលក្រោយទៀត ។  អនីតិជនត្រូវមាន ការយល់ព្រម ពីឪពុកម្តាយ ឬអាណាព្យាបាល ដើម្បីអាចចាក់វ៉ាក់សាំងបាន ។

សព្វថ្ងៃនេះ អ្នកដែលមានអាយុ 12 ឆ្នាំ និងច្រើនជាងនេះ អាចចាក់វ៉ាក់សាំងបាន នៅឡុងប៊ិច ។ ខណៈដែលមិនចាំបាច់ត្រូវមានការណាត់ជួប ទុកជាមុន, អ្នកដែលចង់កំណត់ពេលណាត់ជួប ជាមុន អាចចូល

CITY OF LONG BEACH

# PRESS RELEASE

ទៅ ម៉ាយធើន (My Turn) ដែលជាប្រព័ន្ធណាត់ជួប និងជូនដំណឹង អំពីវ៉ាក់សាំង COVID-19 តាមអ៊ីនធឺណែត របស់រដ្ឋ ឬ ទូរសព្ទទៅលេខ 833.422.4255 ។

ជិល អេ ប៉ែកឃី (Jill A. Baker) ប្រធាន LBUSD បានគូសបញ្ជាក់ថា «យើងខ្ញុំអរគុណ ជាអនេកប្បការ ចំពោះភាពជាដៃគូ ជាមួយសាលាក្រុងឡុងប៊ិច និងនាយកដ្ឋានសុខាភិបាល របស់សាលាក្រុង ក្នុងអំឡុងពេលមានបញ្ហាឆ្លងជំងឺរាតត្បាត ជាសាកលនេះ ។» «វ៉ាក់សាំង បានអនុញ្ញាតឱ្យសាលារៀនអាចបើកដំណើរការឡើងវិញ ឱ្យសិស្ស-និស្សិតមករៀនដោយផ្ទាល់បាន ហើយយើងខ្ញុំចង់រក្សាស្ថានភាពបែបនេះបន្តទៅមុខទៀត សម្រាប់សិស្ស-និស្សិត និងសហគមន៍យើង ។  យើងខ្ញុំនៅតែប្តេជ្ញាចាប់ដៃគូ ជាមួយសាលាក្រុង ដើម្បីផ្តល់ការចាក់វ៉ាក់សាំងទាំងនេះ ឱ្យបានកាន់តែច្រើនឡើង ។»

គ្លីនិកចាក់វ៉ាក់សាំង ចល័ត នៅតាមសាលារៀន គឺជាជំហ៊ានវិជ្ជមាន មួយទៀត ឆ្ពោះទៅធានាឱ្យអាចចាក់វ៉ាក់សាំង ជូនអ្នកគ្រប់គ្នាបាន ។ គ្លីនិកសហគមន៍ ដូចគ្លីនិកទាំងនេះ ផ្តល់ឱកាសផ្ទាល់ សម្រាប់សេវាចាក់វ៉ាក់សាំង ជូនអ្នកដែលមិនអាចធ្វើការណាត់ជួប តាមអ៊ីនធឺណែតបាន ឬ អ្នកខ្វះធនធាន ដើម្បីអាចទៅកាន់គ្លីនិកចាក់វ៉ាក់សាំង ទ្រង់ទ្រាយធំបាន ។ ជាផ្នែកនៃការប្តេជ្ញាចិត្តរបស់ក្រុង ក្នុងការចែកចាយវ៉ាក់សាំង ប្រកបដោយសមធម៌, មន្ទីរសុខាភិបាលបានចាប់ផ្តើមរៀបចំ គ្លីនិកចាក់វ៉ាក់សាំងតូចៗតាមសហគមន៍ ហើយក្រោយមកទៀតបើកដំណើរការ យានចល័ត ចំនួនពីរ ដើម្បីចាក់វ៉ាក់សាំង ជូនប្រជាពលរដ្ឋ នៅតាមភូមិស្ថាន ដែលរងផលប៉ះពាល់ខ្លាំង ពី COVID ដើម្បីកាត់បន្ថយឥទ្ធិពលរបស់វីរុសនេះ ។ ព័ត៌មាន បន្ថែមទៀត អំពីកិច្ចខិតខំប្រឹងប្រែងរបស់ក្រុង ក្នុងការចាក់វ៉ាក់សាំង អាចរកបាននៅ VaxLB webpage ។

សម្រាប់ព័ត៌មានចុងក្រោយបំផុត អំពី COVID-19 ដែលមានសេចក្តីលំអិត អំពីសកម្មភាពទាំងអស់របស់សាលាក្រុងឡុងប៊ិច ក្នុងការរក្សាសុវត្ថិភាព របស់ប្រជាពលរដ្ឋរបស់យើង សូមចូលទៅ longbeach.gov/COVID19 ហើយតាម @LongBeachCity នៅលើ Facebook, Twitter និង Instagram ។ ប្រជាពលរដ្ឋក៏អាចចូលទៅ longbeach.gov/COVID19data ដើម្បីទទួលបានព័ត៌មានបច្ចុប្បន្នភាព ពាក់ព័ន្ធនឹងករណីឆ្លង និងវ៉ាក់សាំង បានផងដែរ ។

# # #